**រាជបណ្ឌិត្យសភាកម្ពុជា**

**មជ្ឈមណ្ឌលសិក្សាចិន**

*អត្ថបទស្រាវជ្រាវ៖*

# «គោលនយោបាយជាតិសំខាន់ៗ របស់ថ្នាក់ដឹកនាំចិន ជំនាន់ទី៥»

*ដោយ៖ លោក* **ម៉ាន គីណាល់**

*ខែមករា ឆ្នាំ២០១៩*

# «គោលនយោបាយជាតិសំខាន់ៗរបស់ថ្នាក់ដឹកនាំចិន ជំនាន់ទី៥»

## *ដោយ៖ លោក ម៉ាង គីណាល់*

*អ្នកស្រាវជ្រាវមជ្ឈមណ្ឌលសិក្សាចិន*

ក្រោយពីលោក ស៊ី ជិនពីង ឡើងកាន់មុខតំណែងក្នុងឆ្នាំ២០១២ ថ្នាក់ដឹកនាំចិន បានកំណត់ និងដាក់ចេញនូវគោលនយោបាយថ្នាក់ជាតិទាំងស្រុងដែលមានយុទ្ធសាស្រ្តប្រាំចំណុចសម្រាប់ផែនការអនុវត្តអាណត្តិទី១ ក្នុងនោះរួមមាន៖

- ទីមួយ៖ បន្តដឹកនាំគោលនយោបាយសេដ្ឋកិច្ចបៃតង ពង្រឹង និងពង្រីកតួនាទីទីផ្សារ និងការវិនិយោគក្នុង ស្រុក។
- ទីពីរ៖បន្តដើរតាមមាគ៌ាសង្គមនិយមតាមចរិតលក្ខណៈរបស់ចិន។
- ទីបី៖បន្តជំរុញមហិច្ឆតាប្រែក្លាយប្រាក់យាន់ឱ្យទៅជារូបិយប័ណ្ណអន្តរជាតិ។
- ទីបួន៖បង្កើនសកម្មភាពនៅតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីកណ្តាល។
- ទីប្រាំ៖បន្តពង្រឹងនិងពង្រីកយ៉ាងពេញទំហឹងនូវកម្លាំងយោធាខ្លាំង។

ដោយឡែក នៅអាណត្តិទី២នេះ កាលពីខែតុលា ឆ្នាំ២០១៧ លោកស៊ី បានប្រកាន់ខ្ជាប់គោលនយោបាយជាតិទំនើបភាវូបនីយកម្មវិស័យចំនួន៤ដើម្បីកសាងប្រទេសជាតិ រួមមាន៖ ទំនើបភាវូបនីយកម្មឧស្សាហកម្ម  ទំនើបភាវូបនីកម្មកសិកម្ម  ទំនើបភាវូបនីយកម្មការពារជាតិ និងទំនើបភាវូបនីយកម្មវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា។ ប៉ុន្តែដោយសារផលប៉ះពាល់នៃបំរែបំរួលនយោបាយសង្គម ដំណើរការអភិវឌ្ឍន៍របស់ចិនមិនទាន់ទទួលបានចំណុចវិជ្ជមាននៅឡើយ។ ចាប់តាំងពីឡើងកាន់អំណាចមក អគ្គលេខាបក្សនិងជាប្រធានរដ្ឋចិន លោកស៊ី ជិនពីង បានលើកឡើងគោលនយោបាយអនុវត្តកិច្ចការ«ទំនើបភាវូបនីយកម្មទី៥» តាមរយៈការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ អនុវត្តខ្លាំងនូវយុទ្ធនាការប្រឆាំងអំពើពុករលួយ និងបង្កើនសុពលភាពនៃប្រព័ន្ធច្បាប់។

ចំពោះមុខការប្តេជ្ញាធ្វើកំណែទម្រង់យ៉ាងខ្លាំងក្លានោះ ប្រទេសចិននារយៈពេល៥ឆ្នាំកន្លងទៅ បានឆ្លងកាត់ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ បញ្ហានៅសេសសល់ជាច្រើនត្រូវបានដោះស្រាយ ដូចជាបង្រួញគម្លាតរវាងអ្នកមាន និងអ្នកក្ររវាងជនបទ និងទីក្រុង ធ្វើឱ្យក្បាលម៉ាស៊ីនបក្ស រដ្ឋស្អាតស្អំតាមរយៈការប្រឆាំងអំពើពុករលួយ និងមានការផ្លាស់ប្តូរវិធីសាស្រ្តអភិវឌ្ឍន៍សេដ្ឋកិច្ចជាដើម។ កាលពីឆ្នាំ២០១៦ ថ្នាក់ដឹកនាំក្រុងប៉េកាំងបានផ្តោតសំខាន់លើយុទ្ធសាស្រ្តនៃគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ចជាតិ៥ចំណុចក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រទេសចិន ដែលជា«ផែន

ការប្រាំឆ្នាំរកិល» លើកទី១៣ មានដូចជា កាអភិវឌ្ឍប្រកបដោយការច្នៃប្រឌិត, ការស៊ីសង្វាក់គ្នា, បៃតង, បើកចំហ, និងការចែករំលែក។

យុទ្ធសាស្ត្រ៥ចំណុច ដែលត្រូវផ្តួចផ្តើមឡើងនៅក្នុងសម័យប្រជុំពេញអង្គលើកទី៥ របស់គណៈកម្មាធិការមជ្ឈិមនៃសមាជប្រជាជនថ្នាក់ជាតិកាលពីខែតុលាកន្លងទៅ បាន និងក្លាយជាមគ្គុទេសក៍សម្រាប់ផែនការ៥ឆ្នាំរំកិលក្នុងអាណត្តិទី១៣នៃរដ្ឋាភិបាលដែលជាផែនការមេមួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិចាប់ពីឆ្នាំ២០១៦រហូតដល់ឆ្នាំ២០២០។ ក្រុមអ្នកស្រាវជ្រាវប្រជុំចទុកផែនការមេនោះ ទៅនឹងមគ្គុទេសក៍យុទ្ធសាស្ត្រមួយដែលស្របស្ថានភាពសេដ្ឋកិច្ចចិនកំពុងឆ្ពោះទៅរកភាពសាមញ្ញថ្មីដែលផ្តោតសំខាន់លើការអភិវឌ្ឍគុណភាពជាជាងបរិមាណយុទ្ធសាស្ត្រថ្មីរបស់ថ្នាក់ដឹកនាំចិន បានទាក់ទាញការចាប់អារម្មណ៍ពីសហគមន៍អន្តរជាតិយ៉ាងខ្លាំងក្រោយពីលោកប្រធានាធិបតីស៊ី ជិនពីង បានបកស្រាយលើចំណុចនីមួយៗនៃយុទ្ធសាស្ត្រនោះនៅកិច្ចប្រជុំកំពូលនៃក្រុមប្រទេសG២០ លើកទី១០ នៅក្រុង Antalya នៃប្រទេសទួកគី កាលពីខែវិច្ឆិកា ឆ្នាំ២០១៥។ ជាក់ស្តែង យុទ្ធសាស្ត្រថ្មីទាំងប្រាំចំណុចនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ចិនក្នុងការធ្វើឱ្យការអភិវឌ្ឍរបស់ប្រទេសចិនកាន់តែល្អប្រសើរជាមួយបណ្តាប្រទេសទូទាំងពិភពលោក ដែលផ្សាភ្ជាប់ជាមួយអភិបាលកិច្ចសេដ្ឋកិច្ចសកល និងបើកចំហកាន់តែទូលាយទៅកាន់ពិភពលោក ផងដែរ។

ជាច្រើនឆ្នាំមកនេះ មេដឹកនាំចិន បានចូលរួមចំណែកការអភិវឌ្ឍសកលយ៉ាងសកម្ម។ តួយ៉ាងគឺថ្នាក់ដឹកនាំចិនបានអនុវត្តនូវសកម្មភាពរបស់ខ្លួន គួរកត់សម្គាល់នៅក្នុងទិសដៅអភិវឌ្ឍន៍សហសវត្សរ៍របស់អង្គការសហប្រជាជាតិ។ ហើយចិនក៏បានបន្តគាំទ្រនូវរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ដែលបានអនុម័តដោយអង្គការសហប្រជាជាតិកាលពីចុងឆ្នាំ២០១៥។ ម្យ៉ាងទៀត លោក ស៊ី ជិនពីង ធ្លាប់បានអះអាងថា ចិននឹងដាក់បញ្ចូលនូវរបៀបវារៈ២០៣០ ជាចំណែកមួយក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរំកិល របស់រដ្ឋាភិបាលនៅក្នុងអាណត្តិទី១៣នេះ ដោយបានស្នើទៅកាន់សមាជិកក្រុមប្រទេសG២០ទាំងអស់ចូលរួមជាមួយនឹងផែនការអនុវត្តរបស់ចិនដើម្បីជំរុញការលូតលាស់សកលកាន់តែខ្លាំងប្រកបដោយចីរភាព និងតុល្យភាព។ ខណៈនៃការកើនឡើងនៃទំនាក់ទំនងការទូតតាមរយៈសាកលភាវូបនីយកម្មសេដ្ឋកិច្ច ប្រទេសទូទាំងពិភពលោកនឹងឃើញកាន់តែច្បាស់ពីការកើនឡើងនៃផលប្រយោជន៍រួមគ្នា។ ជុំវិញបញ្ហាទាំងអស់នេះ គំនិតផ្តួចផ្តើមនៃយុទ្ធសាស្ត្រថ្មីរបស់ចិននឹងផ្តល់ផលវិជ្ជមានសម្រាប់ពិភពលោកនៅពេលប្រទេសនីមួយៗពន្លឿនសេដ្ឋកិច្ចរបស់ខ្លួននោះ។ តាមរយៈការបង្ហាញពីចំណុចសំខាន់នៃយុទ្ធសាស្ត្រនេះ សហគមន៍អន្តរជាតិបានតាមដានកាន់តែខ្លាំង ដោយសង្ឃឹមថា យុទ្ធសាស្ត្រទាំងនេះនឹងនាំមកនូវឱកាសនៃការអភិវឌ្ឍកាន់តែច្រើនថែមទៀត។

លើសពីនេះ ថ្នាក់ដឹកនាំចិនបានប្រកាន់ខ្ជាប់ទស្សនៈកែប្រែរូបមន្តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសចិន ទទួលបានសមិទ្ធផលសំខាន់ក្នុងសភាពការណ៍ដ៏លំបាក ពោលគឺ តម្លៃផលិតផលក្នុងស្រុកសរុប បានកើនឡើងដល់៨០ទ្រីលានយ័នចិន អត្រារួមវិភាគទានសម្រាប់កំណើនសេដ្ឋកិច្ចពិភពលោកលើសពី៣០ភាគរយ

ឧស្សាហកម្មបែបថ្មី ដូចជាសេដ្ឋកិច្ចឌីជីថលទទួលបានការអភិវឌ្ឍយ៉ាងផុលផុស និងការធ្វើទំនើបភាវូបនីយកម្មខាងកសិកម្មមានភាពវិជ្ជមាន។ ប្រទេសចិនមានសមត្ថភាពផលិតឧបករណ៍បច្ចេកវិទ្យាជឿនលឿនមួយចំនួន ដូចជាបន្ទប់ពិសោធន៍អវកាស Tiangong, នាវាមុជទឹកជម្រៅជ្រៅអាចផ្ទុកមនុស្សឈ្មោះ «Dragon», កែវយឺតអវកាសមានទំហំធំជាងគេនៅលើពិភពលោកសញ្ញា«FAST», ផ្កាយរណប DAMPE សញ្ញា «Wukong», ផ្កាយរណប QUESS, និងយន្តហោះខ្នាតធំជាដើម។ យុទ្ធសាស្ត្រនៃការសាងសង់នៅកោះសប្បនិមិត្ត និងថ្មប៉ប្រះទឹកនៃសមុទ្រចិនខាងត្បូងបានដំណើរការយ៉ាងរលូន និងទំហំពាណិជ្ជកម្មជាមួយបរទេស ការវិនិយោគទុននៅបរទេសរួមទាំងរូបិយប័ណ្ណបម្រុងរបស់ប្រទេសចិនសុទ្ធតែស្ថិតក្នុងលំដាប់នាំមុខលើពិភពលោក។ ក្នុងរដ្ឋបាលគ្រប់គ្រងជំនាន់ទី៥ អាណត្តិទី២របស់លោក ស៊ី ជិនពីង ក្រៅអំពីកំណែទម្រង់សេដ្ឋកិច្ច និងសង្គមដែលមិនទាន់ឆ្លើយតបនឹងស្ថានភាពជាក់ស្តែង ទំនងជាគ្មានកំណែទម្រង់គោលនយោបាយទ្រង់ទ្រាយធំណាមួយនឹងត្រូវបានធ្វើនោះទេ។

បើទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះ ចិនគឺជាមហាអំណាចសេដ្ឋកិច្ចពិភពលោកលំដាប់ទីពីរ ហើយអាចនឹងប្រជែងយកឈ្នះអាមេរិកនៅក្នុងរយៈពេលតែ២៥ឆ្នាំខាងមុខ។ ភាពរុងរឿងរបស់ចិននៅពេលនេះ ត្រូវបានប្រវត្តិសាស្ត្រផ្លូវការរបស់ចិនចារទុកថា «ជាស្នាដៃដ៏ធំមហិមារបស់ម៉ៅសេទុង» (ថ្នាក់ដឹកនាំជំនាន់ទី១) ក៏ប៉ុន្តែជាតុពិតជាក់ស្តែង អ្នកដែលបាននាំមកនូវការផ្លាស់ប្តូរពិតប្រាកដហើយដែលជាមូលហេតុដើមធ្វើអោយចិនមានភាពរុងរឿង និងកើនឥទ្ធិពលយ៉ាងឆាប់រហ័សលើឆាកអន្តរជាតិ នៅពេលនេះ គឺ លោក តេង ស៊ាវពីង (ថ្នាក់ដឹកជំនាន់ទី២) និងលោក ស៊ី ជិនពីង (ថ្នាក់ដឹកនាំជំនាន់ទី៥) ឯណោះវិញទេ។

នៅពេលបិទបញ្ចប់មហាសន្និបាតលើកទី១៩ នៃបក្សកុម្មុយនិស្តចិន កាលពីថ្ងៃទី២៤ តុលា ឆ្នាំ២០១៧ លោក ស៊ី ជិនពីង បានសន្យា *«កសាងប្រទេសសង្គមនិយមមួយក្នុងសម័យកាលថ្មីព្រមទាំងមិនលាក់លៀមមហិច្ឆតានាំចិនក្លាយទៅជាមហាអំណាចជួរមុខពិភពលោក ចិននឹងសម្រេចជាសារវន្តគោលដៅក្លាយទៅជាប្រទេសសង្គមនិយមទំនើបនៅឆ្នាំ២០៣៥ និងដល់ឆ្នាំ២០៥០នឹងក្លាយទៅជាមហាអំណាចសង្គមនិយមទំនើបផងដែរ»*។

នេះជារបត់សំខាន់នូវការផ្លាស់ប្តូរនិងអភិវឌ្ឍន៍របស់ប្រទេសចិន ពិសេសប្រព្រឹត្តទៅក្នុងបរិបទដែលប្រទេសចិនកំពុងស្ថិតនៅមុខដំណាក់កាលគន្លឹះមួយដើម្បីសម្រេចគោលដៅកសាងសង្គមសម្បូរធូរធារគ្រប់ជ្រុងជ្រោយ និងជម្រុញការអភិវឌ្ឍសង្គមនិយមដ៏រុងរឿងក្នុងសង្គមចិន។ ហេតុដូច្នេះការផ្លាស់ប្តូរមួយរបស់ចិនមិនត្រឹមតែជះឥទ្ធិពលទៅលើប្រទេសចិនផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបានជះឥទ្ធិពលមិនតិចឡើយដល់ពិភពលោកទាំងមូលទៀតផង៕

## ឯកសារគន្លងនិទ្ទេស


សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានបើកសម័យប្រជុំនៅក្រុងប៉េកាំង លោក ស៊ីជីនភីង ថ្លែងរបាយការណ៍ជូនអង្គសមាជ. China Radio International. Publish 18 October 2017. Available http://cambodian.cri.cn/241/2017/10/18/119s33230.htm

Chi, F. (2014). Decisive Role of the Market. China Reform Research.

Huang, B. & Xia, L. (2018). *China | ODI from the Middle Kingdom: What's next after the big turnaround?* BBVA research. Publish 13 February 2018. Available https://www.bbvaresearch.com/en/publicaciones/china-odi-from-the-middle-kingdom-whats-next-after-the-big-turnaround/

Kiselycznyk, M., & Saunders, P. C. (2010). *Civil-Military Relations in China: Assessing the PLA's Role in Elite Politics*. National Defense University Press. Available https://www.researchgate.net/profile/Phillip_Saunders/publication/235038466_Civil-Military_Relations_in_China_Assessing_the_PLA's_Role_in_Elite_Politics_INSS_China_Strategic_Perspectives_Number_2_August_2010/links/54d376870cf2501791822436.pdf

Mario, E. (2017). The foreign policy of Xi Jinping after the 19th Congress: China strives for a central role on the world stage 2017. REAL INTITUTO: elcano Royal Institute. Publish 7 November 2017. Available http://www.realinstitutoelcano.org/wps/portal/rielcano_en/contenido?WCM_GLOBAL_CONTEXT=/elcano/elcano_in/zonas_in/asia-pacific/ari87-2017-esteban-foreign-policy-xi-jinping-19th-congress-china-central-role-world-stage

Minami, R., Makino, F. (2015). Economic Development in China.

Ning Xin. (2017). China May Resurrect Title of 'Chairman,' Unused Since Mao's Death. Publish 22 August 2017. Available https://www.voanews.com/a/china-title-of-chairman-unused-since-mao/3996897.html

Osamu, T. (2015). Economic Reform and Economic Policy of the Xi Jinping

Ray, J. (2015). *Red China's Capitalist Bomb: Inside the Chinese Neutron Bomb Program*. NATIONAL DEFENSE UNIV FORT MCNAIR DC INST FOR NATIONAL STRATEGIC STUDIES. Available http://www.dtic.mil/get-tr-doc/pdf?AD=ADA617237

Summary of the 19th Communist Party of China National Congress. (2017). TB Bank Financial Group: Newsletter. Action Forex. Publish 26 October 2018. Available https://www.actionforex.com/contributors/fundamental-analysis/52855-summary-of-the-19th-communist-party-of-china-national-congress/

Tay, H. P. (2017). 19th Party Congress: 7 key themes from President Xi Jinping's work report. THE STRAITS TIMES. Publish 18 October 2017. Available https://www.straitstimes.com/asia/east-asia/19th-party-congress-7-key-themes-from-president-xi-jinpings-work-report

Zhang, L., & Tao, K. (2014). The benefits and costs of renminbi internationalization. Available https://www.econstor.eu/bitstream/10419/101217/1/786323620.pdf

Zhang, D. (2017). China becomes world's second-largelargest source of outward. FDI report. Publish 08 June 2017. Available http://www.xinhuanet.com/english/2017-06/08/c_136350164.htm.

## គេហទំព័រផ្សេងៗ៖

http://www.china.org.cn/english/features/state_structure/64401.htm

https://www.ofx.com/en-au/forex-news/historical-exchange-rates/yearly-average-rates/